អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**៧ សីហា ២០១៤**

# សេចក្តីប្រកាសព័ត៌មាន
## នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអ).វ.ត.ក( បានរកឃើញ **នួន ជា** និង **ខៀវ សំផន** មានពិរុទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្ត នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ១៩៧៧ និង បានសម្រេចផ្តន្ទាទោសពួកគាត់ដាក់ពន្ធនាគារអស់មួយជីវិត។

**នួន ជា** គឺជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិអចិន្ត្រៃយ៍។ **នួន ជា** ជាមួយនឹង ប៉ុល ពត មានអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស។ **នួន ជា** បានកាន់តួនាទីជានាយករដ្ឋមន្ត្រីស្តីទីជាផ្លូវការនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាច្រើនដង ពីខែ កញ្ញា ឆ្នាំ១៩៧៦ រហូតដល់ ប៉ុល ពត ចូលមកបន្តកាន់តំណែងនេះឡើងវិញនៅឆ្នាំ១៩៧៧។ ដោយសារតែគាត់មានមុខតំណែងជាន់ខ្ពស់នៅក្នុងជួរថ្នាក់ដឹកនាំរបស់បក្សកុម្មុនីស្តកម្ពុជា **នួន ជា** មានសិទ្ធិត្រួតពិនិត្យលើរាល់សកម្មភាពទាំងអស់របស់បក្ស លើសពីតួនាទី និង ការទទួលខុសត្រូវរបស់គាត់ដែលត្រូវបានប្រគល់ឲ្យជាផ្លូវការ នៅក្នុងអំឡុងពេលនៃរបស់កម្ពុជាប្រជាធិបតេយ្យ។ **ខៀវ សំផន** បានចូលជាសមាជិកបំរុងនៃគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឆ្នាំ ១៩៧១ និង ជាសមាជិកពេញសិទ្ធនៅក្នុងឆ្នាំ ១៩៧៦ ។ គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សពីរនាក់របស់មន្ទីរ ៨៧០ ដែលត្រួតពិនិត្យមើលការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងឋានៈជាសមាជិកម្នាក់នៃមន្ទីរ ៨៧០ គាត់បានទទួលខុសត្រូវលើផ្នែកពាណិជ្ជកម្ម និង គាត់មានតួនាទីសំខាន់នៅក្នុងបញ្ហាសេដ្ឋកិច្ច និងពាណិជ្ជ-កម្មបរទេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅខែ មេសា ឆ្នាំ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធាននៃ គណៈប្រធានរដ្ឋ ដែលជាតួនាទីនិមិត្តរូបដ៏ធំដែលគ្មានអំណាចប្រតិបត្តិ។ ប៉ុន្តែ គាត់បានមានជំនឿទុកចិត្តពីសមាជិកដទៃទៀតជាច្រើនរបស់មជ្ឈឹមបក្ស និង បានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការ អចិន្ត្រៃយ៍ជាច្រើន។

អង្គជំនុំជម្រះបានរកឃើញថា ជាមួយគ្នានឹងសមាជិកជាច្រើននៃគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍ រដ្ឋមន្ត្រីនៃរដ្ឋាភិបាល និង លេខាភូមិភាគជាច្រើន ទាំង **នួន ជា** ទាំង **ខៀវ សំផន** បានចូលរួមក្នុងការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម ដើម្បីសម្រេចគោលបំណងរួមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមដ៏ឆាប់រហ័សមួយ តាមរយៈ"មហាលោតផ្លោះ មហាអស្ចារ្យ" តាមគ្រប់មធ្យោបាយចាំបាច់។ អង្គជំនុំជម្រះបានរកឃើញថា នៅក្នុងចំណោមមធ្យោបាយផ្សេងៗ គោលបំណងរួមនេះត្រូវបានអនុវត្ត តាមរយៈគោលនយោបាយផ្លាស់ទីលំនៅប្រជាជនចេញពីខេត្ត-ក្រុង និងពីតំបន់ជនបទមួយទៅកាន់តំបន់ជនបទមួយទៀត។នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទី១ ជាលទ្ធផលកងទ័ពខ្មែរក្រហមបានបង្ខំឲ្យប្រជាជនយ៉ាងតិច ២ លាន់នាក់ ផ្លាស់ទីលំនៅចេញពីទីក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ ដោយប្រើលេសកុហក់ និងគំរាមកំហែង ដោយភ្ជង់កាំភ្លើង ដោយស្ទើរតែគ្មានប្រាប់ដំណឹងជាមុនអ្វីឡើយ និងដោយបំភិតបំភ័យ និងដោយអំពើហិង្សា។ នៅពេលដែលបណ្ដេញចេញនោះ ប្រជាជនទីក្រុងភ្នំពេញមានភាពខ្សោយយ៉ាងខ្លាំង ដោយសារតែការហ៊ុំព័ទ្ធ ដោយការខ្វះស្បៀងអាហារ។ នៅក្នុងស្ថានភាពចុះខ្សោយនេះ ប្រជាជនត្រូវបានបង្ខំឲ្យដើរទៅតំបន់ដាច់ស្រយាល ក្នុងអំឡុងពេលដែលជាពេលវេលាក្ដៅបំផុតនៃឆ្នាំ និងគ្មានម្ហូបអាហារ ទឹក ថ្នាំពេទ្យ ទីជម្រក ឬ ការដឹកជញ្ជូន។ ប្រជាជនទាំងអស់ដែលរស់នៅក្នុងទីកក្រុងភ្នំពេញត្រូវបានជម្លៀសចេញ ស្ទើរតែគ្មានការលើកលែង រួមទាំង ព្រះសង្ឃ ជនចាស់ជរា និងកុមារ ដែលមានជំងឺនិងមានរបួស ឲ្យចេញពីមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះ និង ស្ត្រីដែលទើបបានសម្រាលកូនរួច។ ពួកខ្មែរក្រហមបានបាញ់សម្លាប់ និងសម្លាប់ប្រជាជនស៊ីវិលស្រស់ៗយ៉ាងច្រើន នៅក្នុងអំឡុងពេលនៃជម្លៀសនោះ ខណៈដែលប្រជាជនជាច្រើនទៀត បានស្លាប់ដោយសារភាពហេវហត់អស់កម្លាំងខ្លាំង អត់អាហារ ឬ ជំងឺ។

នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទី២ នៅចន្លោះខែកញ្ញា ឆ្នាំ១៩៧៥ ដល់ខែ ធ្នូ ឆ្នាំ១៩៧៧ មានប្រជាជនយ៉ាងតិច ៣៣០.០០០ ទៅ ៤៣០.០០០ នាក់ ត្រូវបានបង្ខំឲ្យផ្លាស់ទីលំនៅទៅតាំងទីលំនៅកន្លែងផ្សេងៗ នៅទូទាំងប្រទេសកម្ពុជា។ ប្រជាជនភាគច្រើនត្រូវបានគេបញ្ជាឲ្យចាកចេញពីទីលំនៅរបស់ខ្លួន និង បញ្ជូនចេញដោយមានកងទ័ពខ្មែរក្រហមយាមកាមជាប់ជានិច្ច។ ប្រជាជនណាដែលបដិសេធមិនព្រមចាកចេញ ឬ ប៉ុនប៉ងគេចខ្លួន ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ បង្ខំឲ្យចាកចេញបន្ថែមទៀត។ ប្រជានជនត្រូវបានធ្វើដំណើរតាមមធ្យោបាយផ្សេងៗ រួមមាន ឡាន កាណូត រទេះគោ ឬ ថ្មើរជើង។ ប្រជាជនទាំងនោះត្រូវបានគេឃ្លាំមើលជានិច្ច គ្មានទឹក និងគ្មានម្ហូបអាហារគ្រប់គ្រាន់ និងមិនត្រូវបានអនុញ្ញាតឲ្យយករបស់របរអ្វីជាប់នឹងខ្លួន ឡើយ។ កងទ័ពខ្មែរក្រហមបានយាមកាមជាប់ជានិច្ចចំពោះអ្នកដែលធ្វើដំណើរតាមរថយន្ត ហើយនិងបានបាញ់សម្លាប់ចោល

ចំពោះអ្នកដែលព្យាយាមរត់គេច។ ប្រជាជនខ្លះបានស្លាប់ ដោយសារតែភាពហេវហត់អស់កម្លាំងខ្លាំង អត់អាហារ ឬជំងឺ។

អង្គជំនុំជម្រះក៏បានរកឃើញផងដែរថា **នួន ជា** និង **ខៀវ សំផន** បានអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយកំណត់គោលដៅទៅលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរ។ ជាលទ្ធផលនៃគោលនយោបាយនេះ អ្នករដ្ឋការនៃរបប លន់ នល់ យ៉ាងតិច ២៥០ នាក់ ដែលបានដឹកចេញពីពោធិ៍សាត់ទៅទួលពោធិ៍ជ្រៃ ត្រូវបានសម្លាប់ចោល ភ្លាមៗ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនេះ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថា បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាលដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទី១) ។ ការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាលដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទី២) និង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល តាមរយៈការសម្លាប់អ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ ។ អង្គជំនុំជម្រះក៏បានរកឃើញផងដែរថា នួន ជា និង ខៀវ សំផន បានរៀបចំផែនការ បានញុះញង់ បានជួយនិងជំរុញចំពោះឧក្រិដ្ឋនៃការសម្លាប់រង្គាល (នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទី១ និងទី២)) អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ) (នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន(ដំណាក់កាលទី២)) និងការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ(នៅទួលពោធិ៍ជ្រៃ)។ បន្ថែមពីលើនេះទៀត នួន ជា ត្រូវបានរកឃើញថា បានបញ្ជាចំពោះឧក្រិដ្ឋកម្មទាំងនេះ។ អង្គជំនុំជម្រះបានរកឃើញតែ **នួន ជា** ដែលទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន និង នៅទួលពោធិ៍ជ្រៃ ដែលកត្តានេះត្រូវបានយកមកពិចារណានៅពេលផ្តន្ទាទោស។

នៅក្នុងការសម្រេចអំពីការផ្តន្ទាទោស អង្គជំនុំជម្រះបានពិចារណាទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ រួមទាំងឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានប្រព្រឹត្តឡើង នៅទូទាំងប្រទេស នៅក្នុងអំឡុងពេលជាង ២ ឆ្នាំកន្លះ ប្រឆាំងនឹងជនរងគ្រោះយ៉ាងច្រើនដែលស្ថិតក្នុងចំណោមជនរងគ្រោះដ៏ច្រើនបំផុតនៃរឿងក្តីព្រហ្មទណ្ឌដែលធ្លាប់ត្រូវបានសម្រេច ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ។ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនេះគឺត្រូវបានបង្ហាញឲ្យឃើញ

តាមរយៈលក្ខខណ្ឌនានានៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដែលមានភាពធ្ងន់ធ្ងរ គ្មានការអនុគ្រោះ និងអមនុស្សធម៌។ លើសពីនេះទៀត ឧក្រិដ្ឋកម្មទាំងនេះមានផលវិបាកធ្ងន់ធ្ងរ និងជាប់ជានិច្ចទៅលើជនរងគ្រោះ និងសាច់ញាត់របស់ពួកគេ និងប្រទេសកម្ពុជា ជាទូទៅ។ អង្គជំនុំជម្រះក៏បានរកឃើញនូវស្ថានទម្ងន់ទោសជាច្រើនៈ (នួន ជា និង ខៀវ សំផន គឺជាអ្នកបានទទួលការអប់រំខ្ពង់ខ្ពស់ និងបានដឹងអំពីបច្ច័យនៃអំពើរបស់ខ្លួន ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដោយការរំលោភមុខតំណែងនៃអំណាច និងឥទ្ធិពលរបស់ពួកគេ ហើយជនរងគ្រោះជាច្រើនគឺជាជនងាយរងគ្រោះ និងគ្មានការការពារ និងមានស្ថានសម្រាលតិចតួចបំផុត។ អង្គ-ជំនុំជម្រះបានសម្រេចចផ្តន្ទាទោស នួន ជា និង ខៀវ សំផន ទាំងពីរនាក់ដាក់ពន្ធនាគារអស់មួយជីវិត ដោយកត់សម្គាល់ថា ពិរុទ្ធជនម្នាក់ៗមានសិទ្ធិប្តឹងសាទុក្ខចំពោះការផ្តន្ទាទោសនេះ។

អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះដ៏ច្រើន បានទទួលរងនូវការឈឺចាប់ដែលមិនអាចវាស់វែងបាន រួមទាំងការឈឺចាប់ជារូបវ័ន្ត ការបាត់បង់សេដ្ឋកិច្ច ការបាត់បង់សេចក្តីថ្លៃថ្នូរ ជំងឺផ្លូវចិត្ត និងទុក្ខសោកដោយសារការបាត់បង់សមាជិកគ្រួសារ និង អ្នករាប់អានជិតស្និទរបស់ពួកគេ ដែលជាបច្ច័យនៃឧក្រិដ្ឋកម្មដែល **នួន ជា** និង **ខៀវ សំផន** ត្រូវបានផ្តន្ទាទោសនេះ ។ ហេតុដូច្នេះ អង្គជំនុំជម្រះគាំទ្រលើការអនុវត្តគំរោងសំណងជំងឺចិត្តចំនួន ១១ ដែលបានរៀបចំឡើង សមស្រប ដើម្បីទទួលស្គាល់នូវការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបណ្តាលមកពីការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានជំនុំជម្រះនេះ និងដើម្បីផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាការបញ្ជាក់អំពីការឈឺចាប់នេះ។ គំរោងខាងក្រោមត្រូវបានគាំទ្រៈ ការបង្កើតឲ្យមានទិវាជាតិនៃការចងចាំ ការសាងសង់ស្តូបនៅភ្នំពេញសម្រាប់រម្លឹកដល់ជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំ វិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម ក្រុមជួយខ្លួនឯង ការតាំងពិពណ៌ជា អចិន្ត្រៃយ៍ ការតាំងពិពណ៌ចល័ត និងគម្រោងអប់រំ ការបញ្ចូលជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និង ទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងកម្មវិធីសិក្សារបស់សាលារៀននៅកម្ពុជា ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព គម្រោងបោះពុម្ពកូនសៀវភៅអំពីអង្គហេតុដែលត្រូវបានសម្រេចសេចក្តី និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ការបោះពុម្ពពីរនៃសាលក្រមសំណុំរឿង ០០២/០១ និងគម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក។

សវនាការលើអង្គសេចក្តី នៅក្នុងការជំនុំជម្រះនេះ បានចាប់ផ្តើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងបានបិទបញ្ចប់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ។ នៅក្នុងរយៈពេល ២២២ ថ្ងៃនៃថ្ងៃជំនុំជម្រះនេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់បុគ្គលចំនួន ៩២ នាក់ ដែលរួមមាន ៥៣ចំនួន ហេតុអង្គសាក្សី នាក់ សាក្សី

អត្តចរិតចំនួន ៥ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ នាក់ និងអ្នកជំនាញចំនួន ៣ នាក់។ មានប្រជាជនចំនួន ១០៣.៧២៤ នាក់ ដែលមិនធ្លាប់មានពីមុនមក បានចូលរួមតាមដានការជំនុំជម្រះនេះ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:

Mr. Lars Olsen
Legal Officer
Mobile: +855 (0)12 488 023
Land line: +855 (0)23 861 669
Email: olsenl@un.org

Mr. Neth Pheaktra
Press Officer
Mobile phone: +855 (0)12 488 156
Land line: +855 (0)23 861 564
Email: neth.pheaktra@eccc.gov.kh